Department of Primary Industries

## ការសិក្សាករណី

# រក្សាវាឲ្យបានស្អាត - បន្លែនៅតាមទីវាល

| | |
|---|---|
| សេចក្ដីសង្ខេប | ចំការដែលស្អាត មានសណ្ដាប់ធ្នាប់ល្អ កាត់បន្ថយបញ្ហាសត្វចង្រៃ និងជម្ងឺ |
| សត្វចង្រៃដែលគេច្រើនជួបប្រទះ | សត្វល្អិតចង្រៃ (thrips) ចៃនៅលើរុក្ខជាតិ ដង្កូវមេអំបៅ |
| ជម្ងឺដែលគេច្រើនជួបប្រទះ | ជម្ងឺធ្វើឲ្យស្ងោកស្រពោន និងមានស្នាមអុចៗជាំលើប៉េងប៉ោះ ជម្ងឺដុះផ្សិតពណ៌សលើរុក្ខជាតិដែលនាំឲ្យរលួយស្អុយ ជម្ងឺដុះផ្សិតម្យ៉ាងដែលនាំឲ្យរុក្ខជាតិស្ងោកស្រពោន (fusarium) |
| អ្នកកាន់កាប់ដីធ្លី | Henry Nguyen |
| សហគ្រាស | ចំការបន្លែនៅកន្លែងមួយតូចក្នុងតំបន់ខាងលិច Sydney Basin |





ចំការនេះបានថែទាំឲ្យស្អាត ហើយមានសណ្ដាប់ធ្នាប់ ដោយមានស្មៅឥតប្រយោជន៍តិចតួចបំផុត និងច្រកដើរស្ងួតល្អ។ ការនេះធ្វើឲ្យការប្តូរកន្លែងទៅមក និងបំពេញការងារនៅតាមចំការងាយស្រួល ហើយមានសុវត្ថិភាព។ សត្វចង្រៃ និងជម្ងឺមានកំរិតទាប និងការគ្មានកន្លែងសើម និងអាងទឹក ធ្វើឲ្យការបំពេញការងារជុំវិញចំការងាយស្រួល ហើយមានសុវត្ថិភាព។

### គម្រោង

Henry រៀបចំចំការបានល្អ មានសណ្ដាប់ធ្នាប់ ស្អាត និងគ្រោងការបានល្អ។ គាត់ពុំមែនជាម្ចាស់ចំកាឡើយ ក៏ប៉ុន្តែបានជួលវា ហើយចំពោះគាត់គឺជាការសំខាន់ដែលត្រូវរក្សាវាឲ្យបានស្អាត ហើយមានរបៀបរៀបរយ។ គាត់បានគិតអំពីថាតើត្រូវក្រាលត្រដាងចំការដោយបែបណាដើម្បីឲ្យស្រួលធ្វើការនៅពីក្នុងចំការ ហើយឲ្យគាត់បានចំណេញពេល និងកម្លាំងដោយឲ្យមានអ្វីទាំងអស់រៀបចំបានល្អ និងត្រូវតាមកន្លែង។

### ការជំរុញទឹកចិត្តឲ្យចង់ធ្វើ

“ អ្នកត្រូវថែរក្សាចំការរបស់អ្នក ឲ្យបានដូចជាផ្ទះរបស់អ្នក ”

“វាធ្វើឲ្យអ្នកមានអារម្មណ៍ប្រសើរ និងធ្វើឲ្យការងារនៅតាមចំការស្រួល ហើយមើលទៅទំនងមានល្អ ”

“ការរក្សាវាឲ្យមានសណ្ដាប់ធ្នាប់ ហើយស្អាត ជួយកាត់បន្ថយជម្ងឺប្រសិនបើវានៅក្នុងស្ថានភាពស្អាត ”

“ប្រសិនបើវាគ្មានសណ្ដាប់ធ្នាប់ទេ អ្នកអាចត្រូវម្ចាស់ដីរបស់អ្នកដេញអ្នកចេញពីចំការ”

Production of this factsheet and translations was partially funded by the HAL funded project: *Addressing Product Quality and Safety with LOTE growers of the Vegetable Industry*

Trim referenceINT 12/62501

© State of New South Wales through Department of Trade and Investment, Regional Infrastructure and Services 2010. You may copy, distribute and otherwise freely deal with this publication for any purpose, provided that you attribute the Department of Trade and Investment, Regional Infrastructure and Services as the owner. Disclaimer: The information contained in this publication is based on knowledge and understanding at the time of writing (November 2011). However, because of advances in knowledge, users are reminded of the need to ensure that information upon which they rely is up to date and to check currency of the information with the appropriate officer of the Department of Primary Industries or the user's independent adviser.